**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៨៦៩ ព.ណ.កសម.

## សេចក្តីជូនដំណឹង
## ស្តីពីការដាក់ពាក្យ និងបង់កម្រៃសេវាសាធារណៈ ទាក់ទងនឹងការចុះបញ្ជីម៉ាក

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជូនដំណឹងដល់ ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកទាំងអស់ ឬអ្នកដាក់ពាក្យដែលជារូបវន្តបុគ្គល ឬនីតិបុគ្គល និងសាធារណជនឱ្យបានជ្រាបថា ដើម្បីធានានិរន្តភាពនៃការផ្តល់សេវាសាធារណៈ ក្រសួងពាណិជ្ជកម្មបានចាត់តាំងមន្ត្រីតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលឱ្យប្រចាំការក្នុងការផ្តល់សេវាពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាក។ ទន្ទឹមនឹងនេះដើម្បីចូលរួមអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ក្រសួងពាណិជ្ជកម្ម *សូមផ្អាកជាបណ្តោះអាសន្ននូវការអញ្ជើញមកក្រសួងពាណិជ្ជកម្មដោយផ្ទាល់ ដើម្បីធ្វើការដាក់ពាក្យស្នើសុំបង់កម្រៃសេវាចុះបញ្ជី និងកិច្ចការផ្សេងៗទាក់ទងការចុះបញ្ជីម៉ាក* ក្នុងអំឡុងពេលនៃវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាល។

ដើម្បីជាការជំនួសមកវិញ ក្រសួងពាណិជ្ជកម្ម សូមស្នើ ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកទាំងអស់ និងអ្នកដាក់ពាក្យ (រូបវន្តបុគ្គល ឬនីតិបុគ្គល) និងសាធារណជន ដែលមានបំណងទាក់ទងនឹងការដាក់ពាក្យស្នើសុំការបង់កម្រៃសេវាចុះបញ្ជី និងកិច្ចការផ្សេងៗទាក់ទងការចុះបញ្ជីម៉ាក តាមមធ្យោបាយដូចខាងក្រោម៖

១. សម្រាប់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ដែលបានចុះឈ្មោះ និងទទួលបានគណនី សូមប្រើប្រាស់តាមប្រព័ន្ធដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក www.efiling.cambodiaip.gov.kh ដូចដែលធ្លាប់បានអនុវត្តកន្លងមក។

២. សម្រាប់អ្នកដាក់ពាក្យ (រូបវន្តបុគ្គល ឬនីតិបុគ្គល) ដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាករួចហើយ ឬមានបំណងដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកថ្មី ឬកិច្ចការផ្សេងទៀតទាក់ទងនឹងការចុះបញ្ជីម៉ាក ត្រូវធ្វើឡើងតាមរយៈ Email: marksreception@gmail.com ។ ចំណែកឯកម្រៃសេវាសាធារណៈទាក់ទងនឹងការចុះបញ្ជីម៉ាក ត្រូវបង់តាមរយៈធនាគារណាមួយ ដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | ធនាគារ កាណាឌីយ៉ា (CANADIA Bank) | KHR: 001-000-333-88-22 |
| ២- | ធនាគារ អេស៊ីលីដា (ACLEDA Bank) | KHR: 0001-02-076702-27 |
| ៣- | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) | KHR: 010-01-290-000094-0 |

(រាល់ប្រតិបត្តិការបង់កម្រៃសេវានីមួយៗ តាមរយៈលេខគណនីធនាគារណាមួយខាងលើ សូមបញ្ចូលលេខសម្គាល់ 1518 នៅក្នុងប្រអប់សម្គាល់របស់ប្រព័ន្ធប្រតិបត្តិការរបស់ធនាគារ)។

សេចក្តីជូនដំណឹងនេះ ចាប់ផ្តើមអនុវត្តពីកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងរហូតដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ និងអាចពន្យារពេលតាមការចាំបាច់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព។

ថ្ងៃពុធ ១០កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១

__កំណត់សម្គាល់៖__ 1518 សម្គាល់ក្រសួងពាណិជ្ជកម្ម នាយកដ្ឋានកម្មសិទ្ធិបញ្ញា
__លេខទំនាក់ទំនង៖__ 017 433 393 និង 096 9999 043 (តេឡេក្រាម)